ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០៧៥៤ សជណ ធទឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត តាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា ចាប់ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០១៤ ព្រះរាជាណាចក្រកម្ពុជា នឹងទទួលរងឥទ្ធិពលពីកម្រិតសម្ពាធទាប ដែលអាចបង្កឱ្យមានភ្លៀងកក់ខែ លាយឡំជាមួយផ្គរ រន្ទះ និងខ្យល់កន្ត្រាក់ នៅតាមបណ្តារាជធានី ខេត្ត មួយចំនួនដូចជា : រាជធានីភ្នំពេញ ខេត្តឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ព្រៃវែង ស្វាយរៀង កណ្តាល កំពង់ស្ពឺ តាកែវ ព្រះសីហនុ កែប និងខេត្តកំពត ។ បាតុភូតនេះ ច្រើនកើតមានឡើងនៅពេលរសៀល ។

យោងលើស្ថានភាពអាកាសធាតុ ដូចបានជម្រាបជូនខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមអំពាវនាវដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តារាជធានី ខេត្ត ដូចបានជម្រាបជូនខាងលើ សូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ( ពិសេសនៅពេលរសៀល ដែលផ្ទៃមេឃមានសភាពអាប់អួរកកលភ្លៀង ) ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh